# របាយការណ៍ប្រចាំខែមករា ឆ្នាំ ២០១៧ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែមករា ឆ្នាំ២០១៧ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះបានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. <u>**ស្ថានភាពមន្ត្រីរាជការ**</u>÷

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ សរុបចំនួន ៣០ នាក់ ស្ត្រី ០៣ នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. <u>**សកម្មភាពថ្នាក់ដឹកនាំមន្ទីរ**</u>÷

- ចូលរួមពិធីមីទ្ទិញអបអរសាទរខួបលើកទី៣៨ ទិវាជ័យជំនះ ៧ មករា ថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៧ នៅមន្ទីរវប្បធម៌
- ចូលរួមប្រជុំពិភាក្សាការយកដីក្រហមនៅឃុំសំបុក ដើម្បីស្តារជួសជុលផ្លូវជាតិលេខ៧ ពីក្រចេះទៅស្ទឹងត្រែង ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំចុះពិនិត្យសិក្សា និងប្រជុំបូកសរុបវាយតម្លៃទីតាំង ស្នើសុំសាងសង់ផ្លូវលំនៅចំណុចអូរគគីឃុំឃ្សឹម ស្រុកស្នួល ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ នៅសាលប្រជុំសាលាស្រុកស្នួល
- ចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយ និងដាក់អោយដំណើរការជាផ្លូវការនូវគម្រោងកុមាររាងខ្ពស់ និងធ្ងន់ ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមក្នុងពិធីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០១៦ និងទិសដៅអនុវត្តការងារ ឆ្នាំ២០១៧ ថ្ងៃទី១៧-១៨ ខែមករា ឆ្នាំ២០១៧ នៅសាលមហោស្រពសាលាខេត្ត
- ចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីបើក និងបិទអង្គសន្និបាត បូកសរុបវាយតម្លៃការងារអប់រំយុវជន និងកីឡា ឆ្នាំ២០១៥-២០១៦ ទិសដៅឆ្នាំ២០១៦-២០១៧ ថ្ងៃទី១៩-២០ ខែមករា ឆ្នាំ២០១៧
- ចូលរួមសិក្ខាសាលា ស្តីពីការផ្សព្វផ្សាយ និងបង្កើនប្រសិទ្ធិភាពនៃការអនុវត្តបទបញ្ញត្តិគតិយុត្តពាក់ព័ន្ធសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច ថ្ងៃទី២៣-២៤ ខែមករា ឆ្នាំ២០១៧ នៅខេត្តស្ទឹងត្រែង ។

3. <u>**សកម្មភាពតាមការិយាល័យ**</u>÷

3.1. <u>**ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ**</u>

**ក. ផ្នែកការងារលិខិតចូល÷ សរុបចំនួន ២៣លេខ ក្នុងនោះមាន:**

- លិខិតចូលពីអង្គភាពនានាក្រោមន្ទីរ ចំនួន ១៩លេខ
- លិខិតក្រសួងសាមី និងអង្គភាពក្រោមឱវាទមន្ទីរ ចំនួន០៤លេខ

**ខ. ផ្នែកការងារលិខិតចេញ ÷សរុបចំនួន ៣៨លេខ ក្នុងនោះមាន:**

- លិខិតចេញទៅបណ្តាអង្គភាពនានាក្រោមន្ទីរ ចំនួន ១៣លេខ
- លិខិតចេញពាក់ព័ន្ធស្ថានភាពមន្ត្រីរាជការ ចំនួន ២២លេខ

- លិខិតចេញទូទៅ (លិខិតជូនដំណឹង លិខិតអញ្ជើញ) ចំនួន ០០លេខ
- លិខិតចេញទៅបណ្តាអង្គភាពនានា និងក្រសួងសាមី ចំនួន ០៣លេខ

**គ. ផ្នែកបញ្ជីវត្តមាន÷** ពិនិត្យការចុះបញ្ជីវត្តមានប្រចាំថ្ងៃ ។

3.2. **ការិយាល័យផ្លូវលំជនបទ**

**សកម្មភាពការងារ**

- ក្រុមការងារនាយកដ្ឋានផ្លូវជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ ចុះសិក្សាផ្លូវថែទាំលក្ខណៈខួប ឆ្នាំ២០១៧ ប្រវែង ១៤.៥០គ.ម និងលូកាត់ផ្លូវ ចំនួន៣កន្លែង នៅឃុំស្នួល ស្រុកស្នួល
- ចុះស្រង់ទិន្នន័យផ្លូវជនបទ បានចំនួន១ខ្សែ ប្រវែង៨៥០០ម៉ែត្រ នៅឃុំថ្មអណ្តើក ស្រុកចិត្របុរី ដើម្បីរៀប ចំផែនទីផ្លូវក្នុងខេត្ត
- ចុះធ្វើបច្ចុប្បន្នភាពផ្លូវជនបទបានចំនួន០២ខ្សែ ប្រវែង ៤៨ ២០០ ម នៅឃុំចំបក់ ឃុំតាម៉ៅ ឃុំកំពង់គរ ស្រុកព្រែកប្រសព្វ ។

**លទ្ធផលការងារ**

ការងារចុះស្រង់ទិន្នន័យផ្លូវជនបទ និងធ្វើបច្ចុប្បន្នភាពផ្លូវសម្រេចតាមផែនការ ។

3.3. **ការិយាល័យផ្គត់ផ្គង់ទឹកជនបទ**

សហការជាមួយអង្គការ យូនីសេហ្វ ចុះធ្វើផែនការសុវត្ថិភាពទឹក នៅឃុំថ្មអណ្តើក ស្រុកចិត្របុរី ។

4. **ទិសដៅបន្ត÷**

- ចុះស្រង់ទិន្នន័យផ្លូវ និងធ្វើបច្ចុប្បន្នភាពផ្លូវ នៅស្រុកសំបូរ និងស្រុកស្នួល
- ចុះបំផុសសហគមន៍ ស្តីពីការប្រើប្រាស់ទឹក និងទុកដាក់ទឹកឲ្យមានសុវត្ថិភាព
- ចុះធ្វើបច្ចុប្បន្នភាពអណ្តូង នៅស្រុកចិត្របុរី ។

**ប្រធានមន្ទីរ**